មជ្ឈមណ្ឌលឯកសារកម្ពុជា

# ដើមបណ្តឹងរដ្ឋប្បវេណីបង្កើតសមាគមដើម្បីផ្សព្វផ្សាយពីសិទ្ធជនរងគ្រោះ

ម៉ៃ យើល សាលីបា

ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៩

ប្រែសម្រួលដោយ ឌី សុជាតា

ពីរថ្ងៃ បន្ទាប់ពីកិច្ចប្រជុំពេញអង្គលើកទី៦ នៃគម្រោងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីផ្លាស់ប្តូររបៀបនៃការចូលរួមរបស់ជនរងគ្រោះនាពេលអនាគត ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការសាលាដំបូង កាំង ហ្កេកអ៊ាវ ហៅ ឌុច បានប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណីបានបង្កើតសមាគមដើម្បីផ្សព្វផ្សាយពីសិទ្ធជនរងគ្រោះ ។ ជនរងគ្រោះចំនួន ៣៣ នាក់ (ភាគច្រើនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំនុំរឿង០០១) បានជួបកាលពីព្រឹកមិញ ដើម្បីជ្រើសរើសមន្ត្រី និងប្រកាសអណត្តិនៃអង្គការថ្មីដែលមានឈ្មោះថា «សមាគមជនរងគ្រោះនៃរបបខ្មែរក្រហម» ។ ជុំ ម៉ី ជាអ្នករស់រានមានជីវិតពីគុកទួលស្លែង (មន្ទីរ ស-២១) ត្រូវបានជ្រើសរើសជាប្រធាន ។

ជុំ ម៉ី បានប្រកាសថា គោលបំណងជាបន្ទាន់នៃអង្គការថ្មីនេះ គឺត្រួតពិនិត្យយ៉ាងជិតស្និតចំពោះការវិវត្តនៅ អ.វ.ត.ក និងការបញ្ចុះបញ្ចូលដើម្បីសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី ។ គាត់បន្តថា សមាគមនេះត្រូវបានបង្កើតឡើង ដើម្បីរក្សាការចងចាំទាំងអស់នៃអ្នកដែលស្លាប់ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ និងដើម្បីធានាថាអ្នកជំនាន់ក្រោយនឹងមិនបំភ្លេចអ្វីដែលកើតឡើងក្នុងពេលនោះ ។ ជុំ ម៉ី ពន្យល់ថា សមាគមខិតខំយ៉ាងខ្លាំងដើម្បីផ្តល់ជូននូវសម្ភារៈ និងជំនួយស្មារតីទៅជនរងគ្រោះទាំងឡាយនៃរបបខ្មែរក្រហម ។

ជុំ ម៉ី បានពាំនាំការប្រឆាំងនៃអង្គការរបស់លោក ទៅនឹងសេចក្តីសំរេចនៅពេលថ្មីៗនេះរបស់កិច្ចប្រជុំពេញអង្គ ដែលនឹងត្រូវបានធ្វើជាអ្នកតំណាងរួមដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការវិនិច្ឆ័យទោសនៅ អ.វ.ត.ក នាពេលអនាគត ។ ជុំ ម៉ី បានពន្យល់ថា អង្គការមួយនេះមិនជឿថា សម្លេងតែមួយអាចគ្រប់គ្រាន់ក្នុងការតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលរំពឹងថា នឹងចូលរួមនៅក្នុងការកាត់សេចក្តីលើកទីពីរនៅ អ.វ.ត.ក នោះទេ ។ ជុំ ម៉ី ក៏បានបន្តទៀតថា ដើមបណ្តឹងរដ្ឋប្បវេណីធ្វើពហិកាមិនយល់ព្រម ចំពោះអ្វីដែលចាប់ផ្តើមនៅពេលចេញសេចក្តីសំរេចពីរដងនៅថ្ងៃទី២៧ ខែសីហា ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនអនុញ្ញាតឲ្យសាកសួរសាក្សី ដែលផ្តល់សក្ខីកម្មពីអត្តចរិក ឬក៏ធ្វើការជជែកការពារទាក់ទងនឹងការផ្តន្ទាទោសនោះ ហើយពួកគាត់នឹងបន្តរហូតដល់តុលាការឆ្លើយតបទៅ

នឹងលិខិត ដែលស្នើដោយដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបង្ហាញពីភាពមិនពេញចិត្តរបស់ពួកគាត់ចំពោះសេចក្តីសំរេច ។